# ការសម្ភាសរបស់លោកអ៊ុំស្រី អ៊ុំ យិន

កៈ អ្នកសម្ភាសឈ្មោះ ហែម សីហា ខៈ អ្នកត្រូវបានសម្ភាសឈ្មោះ អ៊ុំ យិន

## <u>ការសង្ខេបរបស់លោកអ៊ុំស្រី អ៊ុំ យិន</u>

ការសង្ខេបពីខ្ញុំបាទ សីហា ខ្ញុំដឹងថាអ្វីទាំងអស់ដែលលោកអ៊ុំស្រី យិន បានចែកចាយជាមួយខ្ញុំបាទ គឺជាការពិតដែលបានកើតឡើងក្នុងឆាកជីវិតរបស់លោកអ៊ុំស្រីមែន។ ខ្ញុំពិតជាមានអារម្មណ៍ក្កកក្តួលនៅពេលបានដឹងជីវប្រវត្តិដ៏កំសត់របស់លោកអ៊ុំស្រី ជាពិសេសនៅពេលដែលខ្ញុំបានដឹងថា សឹងតែពេញមួយជីវិតរបស់លោកអ៊ុំស្រី គឺលោកអ៊ុំស្រីបានជួបតែរឿងពិបាកៗ ឧបសគ្គមិនចេះចប់មិនចេះហើយ។ ប៉ុន្តែទោះបីជាលោកអ៊ុំស្រីបានជួបនូវរឿងពិបាកៗដ៏ច្រើនក្នុងជីវិតក៏ពិតមែន តែអ៊ុំស្រីមិនដែលរាថយនូវរឿងទាំងអស់នោះដែរ គឺលោកអ៊ុំស្វ៊ូជំនះលើវាគ្រប់ពេលវេលាទាំងអស់។ ហើយមានរឿងមួយទៀតដែលធ្វើឲខ្ញុំបាទមានសេចក្តីអំណរចំពោះលោកអ៊ុំស្រីនោះ គឺលោកអ៊ុំស្រីបានស្គាល់ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយលោកអ៊ុំស្រីបាននឹងកំពុងរស់នៅដោយព្យាយាមគោរពបទបញ្ញាតិរបស់ព្រះយេស៊ូវគ្រីស្ទ។)

កៈ ជំរាបសួរលោកអ៊ុំស្រី!

ខៈ ជំរាបសួរក្មួយប្រុស!

កៈ ថ្ងៃនេះត្រូវហ៎! ថ្ងៃទី ២៨ ថ្ងៃអាទិត្យ ខែ មករា ឆ្នាំ ២០១៨។ ខ្ញុំបាទឈ្មោះ ហែម សីហា ធ្វើបទសម្ភាស លោកអ៊ុំស្រីម្នាក់ដែលសព្វថ្ងៃគាត់ កំពុងរស់នៅសង្កាត់ ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ លោកអ៊ុំស្រីដូចជាកម្មវិធីនេះដែលមានឈ្មោះថា គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ហើយវារៀបរាងឡើងដោយអឺ! សាលកវិទ្យាល័យមួយដែលមានឈ្មោះថា Brigham Young University ដែលវាស្ថិត នៅក្នុងអឺ! សហរដ្ឋអាមេរិក ហើយកម្មវិធីនេះគឺទាក់ទងទៅនិងអឺ! ប្រវត្តិផ្ទាល់ខ្លួនរបស់លោកអ៊ុំស្រី។

ខៈ ចាំ!

កៈ ហើយតើលោកអ៊ុំស្រីអនុញ្ញាតឲក្មួយធ្វើកិច្ចសម្ភាសលោកអ៊ុំ ហើយដាក់បញ្ចូលវាទៅក្នុងគេហទំព័រ របស់សាលាដែលមានឈ្មោះថា www.cambodianoralhistories.byu.edu តើលោកអ៊ុំស្រីអនុញ្ញាតឲ ក្មួយធ្វើបទសម្ភាសនេះឬទេ?

ខៈ អនុញ្ញាតឲៗ។

កៈ បាទ! អរគុណច្រើនលោកអ៊ុំស្រី។

ខៈ ចា៎!

កៈ អឺ! អត់ទោសលោកអ៊ុំស្រី តើលោកអ៊ុំស្រីមានឈ្មោះអ្វីដែរឈ្មោះទៅតាមអត្តសញ្ញាណប័ណលោកអ៊ុំ?

ខៈ អត្តសញ្ញាណប័ណ! ដាក់ឈ្មោះដូចនៅក្នុងសាសនាចក្រអញ្ចឹង។

កៈ ឈ្មោះអីដែរ?

ខៈ អ៊ុំ យិន ដដែល។

កៈ អ៊ុំ យិន។

ខៈ ចា៎!

កៈ ហើយលោកអ៊ុំស្រីមានឈ្មោះហៅក្រៅទេលោកអ៊ុំ?

ខៈ អត់ទេ! មានតែមួយហ្នឹងទេ។

កៈ មានតែមួយហ្នឹងទេ។

ខៈ អ្នកណាក៏ស្គាល់ដែរ ហ៊ាស!ៗ។

កៈ ហើយលោកអ៊ុំស្រីមកដល់ឆ្នាំនេះមានអាយុប៉ុន្មានហើយលោកអ៊ុំ?

ខៈ អឺ! បើឆ្នាំខ្មែរគិតជា បើគិតជាឆ្នាំខ្មែរហាស់៧០ ប៉ុន្តែបើគិតឆ្នាំ ១៩៥០ អាយុ ៧៨ អ៎! ៦៨។

កៈ អ៎!

ខៈ ខ្មែរ៧០!

កៈ ខ្មែរ៧០។

ខ៖ ឆ្នាំខ្មែរ!

ក៖ ឆ្នាំបារាំង?

ខ៖ ៦៨។

ក៖ ខុសត្រូវគ្នា២ឆ្នាំ!

ខ៖ ខុសត្រូវគ្នាដើមឆ្នាំចុងឆ្នាំ។

ក៖ អ៎! បាទ! លោកអ៊ុំ។ អឺ! អញ្ចឹងលោកអ៊ុំស្រីកើតនៅឆ្នាំណាដែរលោកអ៊ុំ?

ខ៖ កើតនៅឆ្នាំ ១៩៥០។

ក៖ ឆ្នាំ ១៩៥០! បើគិតជាឆ្នាំច័ន្ទកតិត្រូវជាឆ្នាំអីដែរលោកអ៊ុំ?

ខ៖ ច័ន្ទកតិអីគេ? ឆ្នាំភាសាខ្មែរយើងហ្នឹងអី?

ក៖ សត្វហ្នឹងណា! ត្រូវហ្នឹងសត្វអី?

ខ៖ អ៎! ឆ្នាំ ឆ្លូវ។

ក៖ ឆ្លូវត្រូវនិងហ៎! សត្វអីគេ?

ខ៖ គោ!

ក៖ គោ!

ខ៖ គោ!ៗ ។

ក៖ បាទ! លោកអ៊ុំស្រី។

ខ៖ ឆ្នាំពិតប្រាកដហើយហ្នឹងណា!

ក៖ បាទ!ៗ។ ចុះទីកន្លែងកំណើតរបស់លោកអ៊ុំស្រីនៅណាដែរលោកអ៊ុំ?

ខ៖ នៅអឺ! ភូមិ ប្រាសាទ ឃុំ ចំបក់ ស្រុក បាទី ខេត្ត តាកែវ។ ដាក់តែស្រុក បាទី ខេត្ត តាកែវ ទៅ ឃុំ ចំបក់ ស្រុក បាទី ខេត្ត តាកែវ ទៅ។

ក៖ អ៎! បាទ!ៗ។

ខ៖ នៅភូមិ ប្រាសាទ ឃុំ ចំបក់។

ក៖ ហើយលោកអ៊ុំស្រីមានបងប្អូនប៉ុន្មាននាក់ដែរលោកអ៊ុំ?

ខ៖ ៨នាក់។

ក៖ ៨នាក់។

ខ៖ ប្រុស៤ ស្រី៤។

ក៖ ហើយលោកអ៊ុំជាកូនទីប៉ុន្មានដែរ?

ខ៖ ទី២។

ក៖ ទី២។ លោកអ៊ុំនៅចាំឈ្មោះបងប្អូនទាំងអស់ទេលោកអ៊ុំ?

ខ៖ ចាំទាំងអស់! ប៉ុន្តែស្លាប់អស់អាលីងហើយណា!

ក៖ បាទ!ៗ។ អញ្ចឹងនៅតែលោកម្នាក់ទេសព្វថ្ងៃហ្នឹង?

ខ៖ នៅបីនាក់ នៅប្អូនខ្ញុំមួយសព្វថ្ងៃហ្នឹង ហើយមួយទៀតនៅអាមេរិក ក្រៅពីហ្នឹងស្លាប់អស់អាលីង។

ក៖ អ៎! អញ្ចឹងលោកអ៊ុំជួយប្រាប់ឈ្មោះ បងប្អូនរបស់លោកអ៊ុំទាំង៧នាក់បានទេលោកអ៊ុំ?

ខ៖ បងបង្អស់ឈ្មោះ ងួន ម៉ក់ ងួន។

ក៖ បាទ!ៗ

ខ៖ បន្ទាប់មកខ្ញុំ ខ្ញុំហើយ ម៉ក់ យេម ម៉ក់ យេម ហើយ ម៉ក់ ផល ម៉ក់ ផល ហើយ ម៉ក់ សារុន ម៉ក់ រីម ម៉ក់ សុខា ប្រុសបួនស្រីបួនស្មើគ្នា។

ក៖ ហើយលោកអ៊ុំមាននៅចាំជាពួកគាត់ ស្រុកកំណើតរបស់ពួកគាត់នៅណា? ឬដូចលោកអ៊ុំ?

ខ៖ នៅជាមួយគ្នាទាំងអស់កើតនៅស្រុក ឃុំ ចំបក់ ស្រុក បាទី ជាមួយគ្នា។

ក៖ លោកអ៊ុំនៅចាំអ៊ី! ជាឆ្នាំដែលគាត់កើត?

ខ៖ ឆ្នាំ បងខ្ញុំឆ្នាំ ចបងបង្អស់ហាស់!

ក៖ ឆ្នាំចត្រូវនឹងឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មាន?

ខ៖ មួយពាន់ប្រាំបួនរយសែជាង អត់ដឹងថាសែប្រាំពីរ ឬសែប្រាំបីទេណា។

ក៖ បាទ!ៗ។

ខ៖ ហ្នឹងហើយខ្ញុំឆ្នាំឆ្លូវ ហើយប្អូនរបស់ខ្ញុំស្រីនោះ មួយទៀតនោះបន្ទាប់ខ្ញុំស្រីឆ្នាំថោះ ឆ្លូវ ខាល ថោះ បីឆ្នាំពីរវាញឹកហាស់។

ក៖ អ៎!

ខ៖ បងប្អូនខ្ញុំមកខ្ញុំវាញឹកហ្នុ៎ង បងខ្ញុំដ៏តាប្អូនអាផលមួយទៀតហ្នឹង ប្អូនបន្ទាប់របស់ប្អូនខ្ញុំមួយទៀតហ្នឹងណា ឆ្នាំមមែ ឆ្នាំមមែអាហ្នឹងរង្វើលហើយណា។

ក៖ បាទ!ៗ។

ខ៖ ចា៎! ហើយបានមមែហើយបានប្អូនស្រីមួយទៀតឆ្នាំច ឆ្នាំចហើយបានអារុនឆ្នាំឆ្លូវ ហើយអាពីរនាក់នោះខ្ញុំភ្លេចបាត់ហើយ។

ក៖ បាទ!ៗ។

ខ៖ ខ្ញុំភ្លេចព្រោះវាយូរពេកហាស់។

ក៖ ចុះបងប្អូនថាលោកអ៊ុំថាគាត់ស្លាប់ហ្នឹង លោកអ៊ុំមានដឹងថាគាត់ស្លាប់នៅឆ្នាំណាអីឆ្នាំណា?

ខ៖ អ្ហ៎! ដឹងថាអាមួយ អាមួយឈ្មោះ ម៉ក់ ផល ហ្នឹងស្លាប់ពីពេលទៅពីភ្នំពេញទៅហ៎ា! ពេលទៅពីភ្នំពេញទៅស្លាប់ហ្នុងឆ្នាំ ១៩៧៥ អត់ទាន់កសាងអីសោះយកប្អូនខ្ញុំទៅវ៉ៃចោល ប្អូនខ្ញុំនៅរៀនសោះ!

ក៖ ជំនាន់ពលពត!

ខ៖ ចា៎! ជំនាន់អាពត ដល់អាពេលទៅបាត់ដំបងជាមួយគ្នាទៅទាំងអស់គ្នា អញ្ជឹងក្រុមគ្រួសារខ្ញុំស្លាប់អស់ ហើយកូនចៅខ្ញុំ។

ក៖ បាទ!ៗ។

ខ៖ ប្ដីស្អីស្លាប់អស់ហើយ អញ្ជឹងខ្ញុំទៅបាត់ដំបងជាមួយម៉ែឪខ្ញុំ ជាមួយប្អូនទាំងអស់ហ្នឹងហើយ លើកលែងតែប្អូនខ្ញុំឈ្មោះ ម៉ក់ យេម ទេអត់បានទៅ គេទៅជាមួយប្ដីគេនៅកំពង់ចាមណោះណ៎ា!។

ក៖ បាទ!ៗ។

ខ៖ អញ្ចឹងខ្ញុំទៅបាត់ជំបងខ្ញុំ អ្វយ! វេទនាណាស់ សីហា អត់ចង់និយាយ។

ក៖ បាទ!ៗ។

ខ៖ អត់ចង់និយាយទេ!

ក៖ បាទ!។

ខ៖ ស្លាប់អស់អាលីង អត់មានដឹងកន្លែងទេ អញ្ចឹងដោយសារខ្ញុំអ៊ឺ! ទៅជាមួយគ្នាអញ្ចឹង វាអត់ពេកអញ្ចឹង រត់ទៅជាមួយគ្នាទាំងអស់ ដល់ពេលគេទៅយក គេទៅយកត្រលប់មកកន្លែងដើមវិញហាស់ មកកន្លែង មួយទៀតទេយើងធ្វើស្រែ តែដល់ពេលហើយអញ្ចឹងទៅ ឪពុកខ្ញុំម៉ែឪខ្ញុំរត់ពួនបាន ខ្ញុំរត់ពួនដែរប៉ុន្តែគេរកឃើញ គេរកឃើញប៉ុន្តែក្រៅពីខ្ញុំគេត្រូវវ៉ៃចោលហើយណា!។

ក៖ បាទ!ៗ លោកអ៊ុំ។

ខ៖ គេត្រូវបាញ់ចោលហើយ ដោយសារខ្ញុំស្រី អញ្ចឹងខ្ញុំអត់ព្រមមកតាមគេទេ គេប្រើសុទ្ធតែកម្លាំងយោធា កាលជំនាន់អាពតមិនហៅទាហានទេណា ហៅយោធា អញ្ចឹងគេឲខ្ញុំយកខោអាវយកម៉ុងយកអីយកទៅដេក ខ្ញុំអត់ព្រមយកទេ ខ្ញុំថាខ្ញុំយកខ្ញុំទៅវ៉ៃចោលអញ្ចឹងខ្ញុំអត់យកអីទៅទេ។ ខ្ញុំទៅតែខ្លួនអញ្ចឹងខ្ញុំនិយាយប្រាប់វាថាអញ្ចឹងខ្ញុំអត់មានតក់ស្លត់ទេណា។

ក៖ បាទ!ៗ លោកអ៊ុំ។

ខ៖ ដល់ពេលហើយអញ្ចឹងទៅវាថាអត់ទេ បងកាលហ្នឹងខ្ញុំអាយុជាងម្ភៃទេណា ខ្ញុំក៏ដូចបងដែរខ្ញុំបែកពីគ្រួសារអស់ហើយ អញ្ចឹងអាយោធាហ្នឹងវានិយាយអញ្ចឹងហាស់ គេអត់យកបងឯងទៅវ៉ៃចោលទេ គេយកទៅធ្វើការទេ ថាអញ្ចឹងទៅណា អញ្ចឹងខ្ញុំក៏វានៅចាំខ្ញុំយូរណាស់បានខ្ញុំយកម៉ុងយកភួយខោអាវទៅ មុននឹងបែកគ្នាហ្នឹងខ្ញុំចង់ឃើញមុខឪពុកម្តាយ ចង់ឃើញមុខបងប្អូនណាស់ ដឹងថាត្រូវស្លាប់ហ្នឹងណា។

ក៖ បាទ!ៗ។

ខ៖ ដល់តាពេលហើយអញ្ចឹងទៅវាអត់មានវ៉ៃចោលទេ យកទៅធ្វើការប៉ុន្តែនៅកណ្តាលផ្លូវ កណ្តាលផ្លូវទៅតាមត្រលប់ទៅវិញហ្នឹង កណ្តាលផ្លូវគេប្រជុំគេប្រាប់ថាគ្នាប្រហែល២០០នាក់

មកបានប្រហែលហា ហុកសិបនាក់អីអញ្ចឹងទៅណា ហើយវាថាខ្ញុំនេះរត់ បើសិនជាកុំតែខ្លាចទឹកផឹកមិនកើតកុំអីវាវ៉ៃចោលកន្លែងដងស្ទឹងហ្នឹងហើយវា។

ក៖ បាទ!ៗ។

ខ៖ ហ៊ើ! ដល់អញ្ចឹងហើយគេយកទៅធ្វើការ ហើយខ្ញុំនឹកឪពុកម្ដាយនឹកបងប្អូនណាស់ សីហាអើយ! នឹកម៉ែអានឹក! ទៅដល់ណោះធ្វើការជូនកាលខ្ញុំមានហូប ចង់មកប្រាប់ដំណឹងថាកុំឲម៉ែឪខ្ញុំពិបាកចិត្តទេណា សុំគេមកសុំគេ ហើយយកខោអាវមកអញ្ចឹងមានក្រណាត់ មួយដុំល្អប៉ុន្តែចង់ឲក្រណាត់ហ្នឹងទៅគេឲសំច្បាប់គេ ប្រាប់ម៉ែកុំឲកើតទុក្ខអីខ្ញុំអត់មានស្លាប់អីអញ្ចឹងណា។

ក៖ បាទ!ៗ។

ខ៖ វាអត់ឲទៅទេ ហើយវាក៏អត់យករបស់យើងដែរអញ្ចឹងខ្ញុំនៅហ្នឹង ដល់តាពេលថ្ងៃក្រោយមកខ្ញុំរត់ពីកន្លែងហ្នឹងមួយទៀត ហើយខ្ញុំនៅកន្លែងហ្នឹងខ្ញុំនៅកន្លែងណាក៏ខ្ញុំដើរធ្វើការដែរ ដល់តាពេលធ្វើការបានរស់ តាអត់ធ្វើការនៅតាមភូមិអាហ្នឹងអត់រស់ទេ វាអត់មានអីស៊ីគេផ្ដាច់ស្បៀង វាដាច់ស្បៀងហ្នុងទំរាំបញ្ជូនមកដល់ហ៉ា!។

ក៖ បាទ!ៗ។

ខ៖ នៅសមរភូមិមុខគេឲអង្ករគេឲអីអញ្ចឹង ដល់ពេលហើយអញ្ចឹងខ្ញុំរត់ទៅកន្លែងមួយទៀត ខ្ញុំទៅកន្លែងហ្នឹងចំកន្លែងយោធា អញ្ចឹងធ្វើការទាំងយប់ទាំងថ្ងៃ បាយគេឲហូបហើយដល់តាពេលហើយនឹកឪពុក ម្ដាយសំគេ គេឲទៅគេថាចាំច្រូតហើយ ច្រូតហើយគេថាចាំស្ទូងហើយ ដល់ពេលគេឲទៅឪពុកម្ដាយស្លាប់អស់អាលីង។

ក៖ ហ៊ឺ!!!

ខ៖ ធ្លាប់ពិបាកអញ្ចឹងនឹងហើយខ្ញុំគ្រាន់តែបាននិយាយប៉ុណ្ណឹង។

ក៖ បាទ!ៗ។

ខ៖ ខ្ញុំឈប់និយាយហើយ ឈប់និយាយហើយ ស្លាប់អស់អាលីង។

ក៖ ហើយមិញបងប្អូនលោកអ៊ុំនៅរស់ប៉ុន្មាននាក់?

ខ៖ នៅបីនាក់។

ក៖ បីនាក់។

ខ៖ បីនាក់ទាំងរូបខ្ញុំហាស់។

ក៖ បាទ! ហើយពួកគាត់សព្វថ្ងៃហ្នឹងរស់នៅណាខ្លះ?

ខ៖ ខ្ញុំរស់នៅជាមួយប្អូនខ្ញុំរាល់ថ្ងៃ។

ក៖ ហើយចុះម្នាក់ទៀត?

ខ៖ ម្នាក់ទៀតរស់នៅអាមេរិកហ់! នៅកាលីនៅរដ្ឋកាលី។

ក៖ បាទ!ៗ។

ខ៖ នៅរដ្ឋកាលីអត់ដឹងនៅកន្លែងណាទេ ខ្ញុំអត់ដែលបានសួរគេ។

ក៖ តែគេធ្លាប់ទាក់ទងមកលោកអ៊ុំដែរតើអី?

ខ៖ ហ៊ឺ! ទាក់ទងគេឲ គេផ្ញើរឥវ៉ាន់មកឲស៊ីឲចុកអីអញ្ជឹង ផ្ញើរថ្ងៃមុនខែមុនប្តីគេមក អញ្ជឹងគេផ្ញើរផ្លែឈើផ្ញើរ នំមកឲស៊ី។

ក៖ ចុះម្តាយលោកអ៊ុំស្រីគាត់មានឈ្មោះអ្វីដែរលោកអ៊ុំ?

ខ៖ ចៅ ង៉ែត។

ក៖ ចុះឪពុកវិញលោកអ៊ុំ?

ខ៖ ម៉ក់ ជួង។

ក៖ តែសព្វថ្ងៃគាត់ស្លាប់?

ខ៖ ថាស្លាប់អស់ហើយហ្នឹងថា ស្លាប់នៅបាត់ដំបងទាំងអស់។

ក៖ លោកអ៊ុំមានដឹងថាគាត់ស្លាប់នៅបាត់ដំបង តែនៅឆ្នាំណាដែរ?

ខ៖ ប្រហែល ៧៦។

ក៖ ៧៦!

ខ៖ ឪស្លាប់មុន ម្ដាយស្លាប់ក្រោយ។

ក៖ តែឆ្នាំតែមួយ?

ខ៖ ប្រហែលឆ្នាំតែមួយហើយមើលទៅ គាត់ហើមឪខ្ញុំគាត់ហើម អូ! ឪខ្ញុំហ្នឹងហើមមិនដឹងជាប៉ុន្មានសារហើយសីហាអើយ! ដល់ពេលខ្ញុំមកខ្ញុំទៅធ្វើការនៅទំនប់អញ្ចឹង ខ្ញុំមានស៊ីគេឲស៊ីអញ្ចឹង នៅទំនប់អញ្ចឹងវាសំបូរហូបស៊ី ស៊ីអត់អស់ទេ អញ្ចឹងខ្វះតាម្ហូបអីអញ្ចឹងខ្ញុំទៅយកម៉ែឪខ្ញុំបងប្អូនខ្ញុំមកកន្លែងទំនប់ហ្នឹងហាស់។

ក៖ បាទ!ៗ។

ខ៖ មកយកឲគាត់ទៅធ្វើការអញ្ចឹងគាត់ធ្វើការអត់កើត អញ្ចឹងក៏សំគេត្រលប់ទៅភូមិវិញ អញ្ចឹងក៏ជូនឪនិងត្រលប់ទៅភូមិវិញអីចឹងទៅណា។

ក៖ បាទ!ៗ។ ចុះឪពុកម្ដាយរបស់លោកអ៊ុំស្រីគាត់កើតនៅឆ្នាំណាដែរលោកអ៊ុំ?

ខ៖ ហ៎ូ! អឺ! ម៉ែខ្ញុំបងខ្ញុំ២៥ឆ្នាំ កាលខ្ញុំនៅក្មេងទេណា។

ក៖ ហ៊ឺ!!!

ខ៖ បងខ្ញុំ២៥ឆ្នាំ អញ្ចឹងឪខ្ញុំបងខ្ញុំ បងម៉ែខ្ញុំទៀតអញ្ចឹងខ្ញុំអត់ដឹងឆ្នាំប៉ុន្មានទេ អត់ដែលសួរទេ វាអត់ដឹងស្រុកទេសដល់ប៉ុណ្ណឹងហាស់។

ក៖ បាទ!

ខ៖ វាអត់មាន មែនដូចគេមានកំនត់ហេតុអីចឹងអត់ទេ។

ក៖ ហើយលោកអ៊ុំមានដឹងថាពួកគាត់មានស្រុកកំណើតនៅណាទេ?

ខ៖ នៅស្រុកជាមួយគ្នាហ្នឹងណា។

ក៖ ស្រុកតាកែវហ្នឹងហ្មង?

ខ៖ ចា៎! នៅឃុំ ចំបក់ ហ្នឹងនៅស្រុកជិតៗគ្នាហ្នឹង។

ក៖ តែមិញអឺ! លោកអ៊ុំថា ម្ដាយលោកអ៊ុំបងលោកអ៊ុំ២៥ឆ្នាំអញ្ចឹង។

ខ៖ ម៉ែខ្ញុំបងខ្ញុំ២៥ឆ្នាំ។

ក៖ លោកអ៊ុំអាយុ២៥!

ខ៖ ម៉ែខ្ញុំការ ម៉ែខ្ញុំអាយុ៥០។

ក៖ អ៎!

ខ៖ ម៉ែខ្ញុំអាយុ៥០ហ្នឹងហើយ ទៅកំពតអាយុហាសិបជាងទេ។

ក៖ បាទ!ៗ។

ខ៖ បងខ្ញុំ២៥ ម៉ែខ្ញុំការក្មេង ពីក្មេងអាយុ២០អីហ្នឹង។

ក៖ បាទ!ៗ។ ហើយកាលពីឪពុករបស់លោកអ៊ុំស្រីគាត់នៅរស់ហ្នឹង គាត់ប្រកបមុខរបរអីដែរ?

ខ៖ ធ្វើស្រែ។

ក៖ ធ្វើស្រែ ហើយអត្តចរិកគាត់ជាមនុស្សយ៉ាងមិចវិញ?

ខ៖ អូ! ម៉ែឪខ្ញុំស្លូតណាស់ ឪខ្ញុំស្លូតណាស់ ស្រឡាញ់កូនណាស់ណា អញ្ចឹងគ្រាន់តែបែកអញ្ចឹង កូនមួយគេយកទៅវៃចោលនៅចំបក់ហ្នឹងណា នៅស្រុកទៅដល់ហ្នឹងពិបាកចិត្តចង់ង៉ាប់ហើយ គាត់ស្គមហើយដល់ពេលទៅបាត់ដំបង
គេយកខ្ញុំទៅទៀតគាត់ពិបាកចិត្តដេកពេទ្យអត់ធ្វើការអញ្ចឹងស្លាប់បណ្តោយ។

ក៖ បាទ!ៗ។

ខ៖ នៅស្រុកគេតាអត់ធ្វើការស្លាប់ណា នៅជំនាន់អាពត ដេកពេទ្យមានណាគេផ្តល់ គេផ្តល់អាហារទៅតែអ្នកមុខ។

ក៖ ចុះម្តាយរបស់លោកអ៊ុំស្រីគាត់ កាលគាត់នៅរស់គាត់ប្រកបមុខរបរអ្វីដែរ?

ខ៖ ធ្វើស្រែដែរ។

ក៖ ធ្វើស្រែ។

ខ៖ ចាំមើលសីហាឯង! ខ្ញុំជំនាន់អាពតហ្នឹងខ្ញុំលើកទឹកចិត្តឪខ្ញុំណាស់ណា ខ្ញុំប្រាប់ឪខ្ញុំថា ឪឯងកុំអស់សង្ឃឹមណាឪគ្មានអាណាទុកស្រុកទេសធ នៅអញ្ចឹងទេ
ខ្ញុំនិយាយប្រាប់គាត់គ្រប់បែបយ៉ាងណា!។

ក៖ ហ្នឹង!

ខ៖ ខ្ញុំប្រាប់គាត់អញ្ចឹងហើយគាត់ព្រមតស៊ូ ដល់តាអស់ពីខ្ញុំទៅអត់មានអាណាលើកទឹកចិត្តហាស់ ពិបាកចិត្តមានតែខ្ញុំដើររកចិញ្ចឹមសីហា!។

ក៖ បាទ!ៗ។

ខ៖ ជំនាន់អាពត។

ក៖ ហើយចុះលោកអ៊ុំស្រីអឺ! ពួកគាត់មានធ្លាប់ដែលនិយាយរឿងពីជីវិតរបស់ពួកគាត់ប្រាប់លោកអ៊ុំស្រីទេ?

ខ៖ អត់មាននិយាយអីផង! ហ្នឹងហើយអត់ធ្លាប់និយាយអីសោះ។

ក៖ ប្រវត្តិគាត់នៅក្មេងៗ?

ខ៖ ខ្ញុំអត់មានស្គាល់ជីតាខាងម៉ែខ្ញុំអត់ស្គាល់ទេ ឪពុកខាងម៉ែខ្ញុំ ខ្ញុំអត់ស្គាល់សោះស្លាប់អស់អាលឹងឪពុក ឪពុកម្ដាយខាងឪខ្ញុំក៏ខ្ញុំអត់មានស្គាល់ដែរ គាត់ស្លាប់ទាំងពីក្មេងៗមកអត់ដឹងថា អត់ដែលនិយាយ។

ក៖ អញ្ចឹងលោកអ៊ុំអត់ស្គាល់ឈ្មោះជីដូនជីតាទេចឹង?

ខ៖ ស្គាល់តាជីដូនជីតាខាងឪ ដល់តាពេល!

ក៖ គាត់មានឈ្មោះអីដែរ?

ខ៖ អឺ! ខ្ញុំស្គាល់តាឈ្មោះឪខ្ញុំឈ្មោះ តា ម៉ក់ ឪរបស់ឪខ្ញុំណាហើយ។

ក៖ តា ម៉ក់។

ខ៖ តា ម៉ក់ ហើយដល់តាពេលម្ដាយរបស់ឪខ្ញុំឈ្មោះ យាយ ទូច។

ក៖ ចុះខាងម្ដាយអត់ស្គាល់?

ខ៖ ម្ដាយឈ្មោះ យាយ លុយ ហើយប្ដីយាយ លុយ ឈ្មោះ តា ចៅ។

ក៖ បាទ!ៗ។

ខ៖ តាប៉ុណ្ណឹងស្គាល់បានត្រឹមម៉ាជំនាន់ហ្នឹងណាអត់បានច្រើន។

ក៖ មានដឹងថាពួកគាត់កើតនៅឆ្នាំណាអី? ស្រុកកំណើតពួកគាត់អត់?

ខ៖ គាត់បើតាមខ្ញុំស្តាប់គាត់និយាយអឺ! ម្តាយរបស់ខ្ញុំកាត់ចិន ឪពុកម្តាយខាងម៉ែខ្ញុំណាកាត់ចិន។

ក៖ បាទ!ៗ។

ខ៖ ហើយដ៏យាយម្តាយយាយខាងម៉ែខ្ញុំកាត់វៀតណាម អញ្ចឹងម៉ែខ្ញុំហើយដ៏តាឪខ្ញុំខ្មែរសុទ្ធហ្នឹង។

ក៖ ហើយលោកអ៊ុំអត់ដឹងស្រុកកំណើតគាត់នៅណា?

ខ៖ អត់ដឹងទាំងអស់ហាស់! ខ្ញុំដឹងថាកើតមកនៅស្រុក គេហៅខ្ញុំថាអាចិនពាំងហ៊ីងៗអញ្ចឹងណាហាស់!!។

ក៖ បាទ!ៗ។

ខ៖ ហាស់!!!ៗ ហើយឃើញចិនៗភាសខ្លួនមកពីស្រុកចិនមក អញ្ចឹងនៅជិតភូមិម៉ែខ្ញុំដ៏ពេលហើយអញ្ចឹងគេអត់ចង់ធ្វើ ពួកចិនៗវាអត់ធ្វើស្រែវានៅផ្សារអស់អាលីង ម៉ែខ្ញុំនៅតែធ្វើស្រែ។

ក៖ ហើយលោកអ៊ុំស្រីអត់មានដឹងរឿងរបស់ជីដូនជីតាខ្លះៗទេ?

ខ៖ អត់! អត់ដឹងសោះព្រោះអត់មាននិយាយប្រាប់ ដល់ពេលទៅអាពតខ្ញុំនៅក្មេងដែរហ្នឹង។

ក៖ ហ៊ឺ!

ខ៖ អត់មាននិយាយប្រាប់សោះ គ្រាន់ដឹងថាហ៊ឺពិបាកណាស់!

ក៖ ចុះលោកអ៊ុំមករស់នៅភ្នំពេញហ្នឹងរយៈពេលយូរប៉ុណ្ណាហើយ? ចេញពីតាកែវមក?

ខ៖ ចេញពីតាកែវ អត់ទៅតាកែវចេញមកពីអាពតខ្ញុំអត់មានមកស្រុកទេ អត់មានមកភ្នំពេញទេ ខ្ញុំទៅន់! ទៅលិចវិញទេ។

ក៖ ហ៊ឺ!

ខ៖ ទៅនៅអូយ! ខ្ញុំកំសត់ណាស់ចេញមកខ្ញុំអត់លុយអីម៉ារៀល អត់មានខោអាវស្លៀកពាក់អីទាំងអស់ នៅអាពតខ្ញុំជាប់គុកហាស់ គេមិនហៅគុកទេមន្ទីរកសាង អញ្ចឹងខ្ញុំជាប់មន្ទីរកសាងដោយសារខ្ញុំលែងចង់រស់ នៅជំនាន់អាពតខ្ញុំលែងចង់រស់ទៀតហើយណា។

អញ្ជឹងដល់តាពេលគេយកខ្ញុំទៅគេសួរខ្ញុំថានៅស្រុកណា? ខ្ញុំថានៅតាកែវ ជំនាន់អាពតគេមិនហៅថាកែវ គេហៅស្រុក៥៤អញ្ជឹង ដល់ម្នាក់ហ្នឹងសម្ភាសសួរខ្ញុំអញ្ចឹងហ៊ី! អញ្ចឹងគេវានៅយោធាហ៎ា! វានៅស្រុកតាកែវដែរដ៏អញ្ចឹង វាប្រាប់ថានៅកន្លែងណាអញ្ចឹងភូមិ ឃុំត្រពាំងក្រសាំង ហើយសួរខ្ញុំថានៅណាអញ្ជឹង ខ្ញុំថានៅឃុំ ចំបក់អញ្ចឹងដល់ហើយអញ្ចឹងវាអត់ជឿ វាអត់ជឿថាខ្ញុំនៅស្រុកហ្នឹងហោះ! វាថាឲខ្ញុំរៀបរាប់អឺ! ស្រុកនៅបាទីហ្នឹងណារៀបរាប់ប្រាប់ឃុំឲវា ខ្ញុំថាអូយ!ខ្ញុំភ្លេចអស់ហើយ ខ្ញុំខ្វិលនិយាយជាមួយវាខ្ញុំថាអញ្ជឹងណា។

កៈ បាទ!ៗ។

ខៈ ខ្ញុំភ្លេចអស់ហើយហេ! អត់ទេឲរាប់ឲបានខ្លះ ខ្ញុំថាឃុំ ចំបក់ ឃុំ រាំងសាទអីចឹងទៅណា វាមានឃុំប៉ុន្មាន ត្រពាំងក្រសាំងអីចឹងទៅដល់ពេលហើយវាថាបានវាជឿ វាជឿខ្លាចយើងឆ្លើយតាពីតាពាសហាស់។

កៈ បាទ!ៗ។

ខៈ ប៉ុន្តែដល់ពេលហើយអញ្ចឹងទៅ អូយ! សីហាអើយ! វាយល់ខ្ញុំអីយល់ម្លេះ! វាយល់ថាអ្នកស្រុកដូចគ្នាហាស់ យោធាគេហៅយោធា វានៅយាមវានៅកន្លែងធ្វើការដូចថាគេចាប់យើងដើរសេរីអញ្ជឹង ឬក៏អ្នកភូមិហ្នឹងសេរី បេះបន្លែបេះផ្លែឈើខ្លួនឯងធ្វើស៊ីឯកជនក៏គេចាប់ដាក់ហ្នឹងដែរណា។

កៈ បាទ!ៗ។

ខៈ ហ្នឹងហើយដល់តាពេលហើយខ្ញុំនៅហ្នឹង នៅហ្នឹងវាយល់មែនទែនសីហាអើយ! អូ! វាមានស្អីក៏វាឲស៊ីដែរ អត់ឲស៊ីបាយចូលជាមួយអ្នកទោស ជាមួយអ្នកនេះវាទេណា។

កៈ បាទ!។

ខៈ វាឲវាប្រជុំគ្នាវាខ្ញុំលឺសួរ វាឲស៊ីដោយខ្លួនពីគេ ហើយដល់ពេលហើយអញ្ចឹងពេលយប់ស្ងាត់អញ្ជឹង ខ្ញុំមានស្រីប្អូនខ្ញុំម្នាក់ប្អូនខ្ញុំមីនៅអាមេរិកហ្នឹង ប្អូនខ្ញុំម្នាក់ហើយខ្ញុំនិងពួកម៉ាកប្អូនខ្ញុំម្នាក់ទៀតបីនាក់ ពេលស្ងាត់អញ្ចឹងវាយករបបវាមកឲស៊ីនៅពេលយប់ អញ្ជឹងមានគេចែកស្អីអញ្ជឹងវាយករបស់វាមកឲស៊ី ខ្ញុំនៅហ្នឹងមួយអាទិត្យ

ដល់ពេលនៅហ្នឹងមួយអាទិត្យ ពេលគិតទៅគេយល់ណាស់ជំនាន់អាពតដល់តាពេលបែកគ្នាអញ្ចឹងបានយល់ស្រុកតាកែវអញ្ចឹងអាពតហាស់។

ក៖ បាទ!ៗ។

ខ៖ ពេលកំពុងអាពតវាស្លូត មនុស្សវាសុទ្ធចាប់ហែកហាស់វាបោកហាស់ខ្ញុំលឺស្ងួរបងប្អូនខ្ញុំនិយាយដល់ខ្ញុំ ត្រឡប់មកវាថា អូ! ខ្ញុំនិយាយប្រាប់ទៅជួបអ្នកស្រុកយើងប៉ុន្តែអត់ស្គាល់ទេ បែបស្លាប់ក៏មិនដឹងទេវាថាហើយចិត្តល្អណាស់វាអញ្ចឹងហាស់ វាថាពួកអាហ្នឹងសុទ្ធតាសាហាវមនុស្សសុទ្ធតាចាប់បោកហើយកូនង៉ែតសុទ្ធតែចាប់ហែក ហើយដំទៅស្រុកគេវាព្រ័តប្រាស់ដូចយើងដែរហាស់ប្រាប់ខ្ញុំអញ្ចឹងវាថា។

ក៖ បាទ!ៗ។

ខ៖ ខ្ញុំក៏ព្រ័តប្រាស់ដូរបងឯងដែរ ព្រ័តប្រាស់ម៉ែខ្ញុំមានកូនតែមួយទេអីចឹងវានិយាយមានកូនតែមួយទេហើយបែកគ្នាអស់ហើយអីចឹង ដំតាហើយអញ្ចឹងទៅខ្ញុំធ្វើការនៅហ្នឹងមួយអាទិត្យ ពេលធ្វើការហ្នឹងម៉ោងដប់ពីរម៉ោងមួយបានគេឲចុះ តាំងពីព្រឹកព្រលឹមប៉ុន្តែពេលកំពុងតែធ្វើការម៉ោងដប់អីអញ្ចឹងវាដុតជំឡូងអីឲស៊ីហាស់ពួកវាយល់ ដល់ពេលថ្ងៃមួយគេផ្លាស់ខ្ញុំ គិតទៅអាយុខ្ញុំអត់ត្រូវអស់ទេសីហាអឺ! គេផ្លាស់ខ្ញុំប្តូរទៅកន្លែងមួយផ្សេងទៀត គេចង់ឲយើងទៅសហាករដើមវិញដែលយើងថារត់គេចពីកន្លែងហ្នឹងហាស់ វាប្រដៅខ្ញុំប្អូនខ្ញុំទៅធ្វើការអស់ហើយវាទុកខ្ញុំម្នាក់អញ្ចឹងវាប្រដៅ វាប្រាប់ថាបងឯងកុំរត់អង្គការដាក់នៅកន្លែងណានៅកន្លែងហ្នឹងហើយកុំទៅណាឲសោះ បើសិនជាបងឯងរត់បងឯងគេវៃបងឯងង៉ាប់ហើយ វាប្រដៅយើងសព្វគ្រប់ហាស់។

ក៖ បាទ!ៗ។

ខ៖ អូយ! ប្រដៅអើយប្រដៅ អូ! វាមានកន្សែងមួយ វាមានក្រម៉ាអញ្ចេះក្រម៉ារបស់យើងហ្នឹងថ្មីហើយវា ខ្ញុំវាមានក្រម៉ារបស់ខ្ញុំដែរហើយពួកម៉ាកខ្ញុំវាអត់មានប្អូនខ្ញុំមានដែរហើយអញ្ចឹងវាឲទៅម្នាក់ដែលអត់ហាស់ វាខ្សឹបប្រាប់ថាកុំឲច្រណែនគ្នាខ្ញុំថាអូយ!អត់ច្រណែនទេ វាសុទ្ធតែនិយាយហាស់ពួកវា។

ក៖ បាទ!ៗ។

ខ៖ ហ្នឹងហើយដល់ពេលជួបគ្នាឯងអញ្ចឹង ដល់ពេលវាបែកគ្នាអញ្ចឹងបានវាដឹងវាចេះតែនឹកគ្នានៅស្រុកកាលពីអត់ទាន់បញ្ជូនវាមកហ្នឹងហាស់។

ក៖ បាទ!ៗ។

ខ៖ វាខុសសម្លាប់មនុស្សរហូតសម្លាប់មនុស្សហាស់។

ក៖ ហើយលោកអ៊ុំអឺ! សាច់ញាតិលោកអ៊ុំដែលរស់នៅស្រុកក្រៅហ្នឹងត្រូវជាប្អូនលោកអ៊ុំ?

ខ៖ ប្អូនបង្កើតហាស់។

ក៖ មិញគាត់រស់នៅណា?

ខ៖ នៅកាលីហ្វ័កញ៉ាប៉ុន្តែអត់ដឹងថានៅរដ្ឋៗ!

ក៖ រដ្ឋកាលីហ្វ័កញ៉ា!

ខ៖ រដ្ឋកាលីហ្វ័កញ៉ាប៉ុន្តែអត់ដឹងថាកន្លែងគេហៅស្អីទេ ខ្ញុំអត់ដឹងទេណា។

ក៖ ហ្នឹងៗ។

ខ៖ ដំតាសួរក្មួយខ្ញុំបានដឹង។

ក៖ ហើយលោកអ៊ុំអត់ទាន់រៀបមានគ្រួសារមានអីណា?

ខ៖ ខ្ញុំមានតើមានកូនហើយតែស្លាប់អស់ហើយហ្នឹង។

ក៖ ហើយស្វាមីលោកអ៊ុំមានឈ្មោះអីដែរអញ្ចឹង?

ខ៖ ម៉ក់ ផល។

ក៖ ម៉ក់ ផល! កាលហ្នឹងលោកអ៊ុំស្រីរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំណាដែរលោកអ៊ុំ?

ខ៖ មួយពាន់ប្រាំបួនរយប៉ុន្មានទេភ្លេចបាត់ហើយ! មួយពាន់ប្រាំបួនរយ ខ្ទង់ចិតសិបមានកូនចិតសិបពីរ អូ! ភ្លេចអស់ហើយ!។

ក៖ ៧២មានកូនប្រហែលជា!

ខ៖ មានកូនពីរនាក់។

ក៖ អាយុប៉ុន្មានហើយការហ្នឹង? មានកូន៧២ហ្នឹង?

ខ៖ កូនៗហ្នឹងអាយុពីរបីឆ្នាំមួយ ពីរបីឆ្នាំមួយខ្ញុំភ្លេចបាត់អស់ហើយណា ពីរឆ្នាំភ្លេចអស់ហើយបងប្អូន។

ក៖ ហើយចុះអ៊ី! អាពាហ៍ពិពាហ៍ដែលធ្វើឡើងហ្នឹងរៀបចំឡើងដោយឪពុកម្ដាយ ឬក៏ពលពតជាអ្នកចាប់ផ្ដុំ?

ខ៖ អត់ទេ! ឪពុកម្ដាយ។

ក៖ ឪពុកម្ដាយ!

ខ៖ ទៅដល់ពលពតហ្នឹងគេឲរៀបឲទៀតតើខ្ញុំអត់យក ខ្ញុំគេចាប់ការអាឆ្នាំ៧៨ ចាំ! ចាប់រៀបឲហ្នឹងខ្ញុំប្រាប់ថាខ្ញុំយកអត់កើតទេពីព្រោះ ខ្ញុំឈឺបេះដូងអីចឹងទៅកាលណា ខ្ញុំឈឺបេះដូងយកប្ដីអត់បានទេ។

ក៖ បាទ!

ខ៖ ប្រាប់គេអញ្ជឹង ហ្ន៎! មិនអីចឹងព្រោះអាយុច្រើនហើយអង្គការវាឲរៀបការអីចឹងគេត្រូវតែចាប់ដាក់ហាស់ គឺគោលនយោបាយគេ គេមិនឲនេះទេអញ្ជឹងគេដាក់ឲ។

ក៖ ហើយលោកអ៊ុំមានកូនប៉ុន្មាននាក់អញ្ជឹង?

ខ៖ ពីរ!

ក៖ ពីរនាក់តែសព្វថ្ងៃគាត់?

ខ៖ ស្លាប់អស់ហើយហ្នឹង ថានិយាយធ្វើអី។

ក៖ ហើយការរៀបអាពាហ៍ពិពាហ៍ហ្នឹងលោកអ៊ុំមានយកជំនូនគេអត់កាលហ្នឹង? ថ្លៃជំនូន?

ខ៖ អូ! យកតើ។

ក៖ យកប៉ុន្មានដែរកាលហ្នឹង?

ខ៖ យកបន្តិចបន្តួចដែរហ្នឹង តែយកមិនថ្លៃប៉ុន្មានដែរហ្នឹង មនុស្សប្រុសកាលហ្នឹងមានតម្លៃណាស់ណា។

ក៖ បាទ!ៗ លោកអ៊ុំ។ អញ្ជឹងដូចជាក្មួយចង់ឲលោកអ៊ុំនិយាយប្រាប់ខ្លះៗពីអ៊ី! គ្រាដំបូងដែលលោកអ៊ុំ និងស្វាមីលោកអ៊ុំបានជួបគ្នាលោកអ៊ុំ មូលហេតុអី?

ខ៖ អូ!!!

ក៖ សាច់រឿងខ្លះៗបានជួបជាមួយស្វាមី?

ខ៖ អើ!ៗ អាហ្នឹងមែនយើងទាក់ទងគ្នាមុនទេណា មិនមែនដូចឥឡូវទេអឺ! ដូចឪពុកម្ដាយអ្នកទុកដាក់ទេណា ដូចថាខាងកូនកំលោះហ្នឹងគេដើរមើលដើររកប្រពន្ធអញ្ចឹង គេមិនដើរមើលតាមនេះអញ្ចឹងកាលណាគេពេញចិត្តគេមិនសួរ គេលបខ្ញុំវិញមិនមើលខ្ញុំបានទៅមើលដោយជំរាបសួរទេ សុទ្ធតែលបមើលដំតាមើលចដឹងខ្លួនខ្ញុំរត់ហើយពីក្មេងហាស់ ពេលកំពុងស៊ីបាយគេនាំមនុស្ស ហាស់!!!ៗ រត់ចោលចានបាយបាត់ហើយអត់នៅទេអត់ឲអ្នកឯងមកមើលនេះទេអត់ទេ ហើយដំកើតគេថាចេះ អូ! អ្នកស្រុកថាហេ!វាទៅរៀនមនុស្សច្រើន ប្រុសៗក៏ច្រើន ស្រីៗក៏ច្រើន វាអត់ចេះខ្មាស់គេទេ ហើយដំតាគេគ្រាន់មកអញ្ចឹងមិចក៏ខ្មាស់អញ្ចឹងហាស់។

ក៖ ហ្នឹងហើយ អញ្ចឹងមូលហេតុអីបានខាងគ្រួសារលោកអ៊ុំអាចទាក់ទងលោកអ៊ុំបាន? ហាស់!!!ៗ។

ខ៖ ដំតាសួរម៉ែឪអញ្ចឹង ម៉ែឪអឺ! យើងតាមម៉ែឪដែរប៉ុន្តែតាមដែរដំតាយើងពេញចិត្តដែរណា។

ក៖ អត់មានអនុសាវរីយ៍អីទេ?

ខ៖ អត់មានអនុសាវរីយ៍អីទេអត់មានទាក់ទងគ្នាល្អកល្អឺនអញ្ចឹងដូចសព្វថ្ងៃអញ្ចឹងទេ អត់ទេអត់មាននាំគ្នាដើរលេងដូចសព្វថ្ងៃទេ អត់ទេអត់សោះ។

ក៖ បាទ!ៗ ហាស់!!!

ខ៖ ប្រពៃណីមែន អានេះយកប្រពៃណីខ្មែរហ្នុងហាស់។

ក៖ បាទ!ៗ។

ខ៖ ចំហ្នុង!

ក៖ ហើយលោកអ៊ុំរៀនភាសាខ្មែរបានកំរិតណាដែរលោកអ៊ុំ?

ខ៖ ខ្ញុំរៀនថ្នាក់ទី ខ្ញុំជាប់ឌីផ្លូមឈប់។

ក៖ ឌីផ្លូមសម័យហ្នឹង!

ខ៖ សម័យហ្នឹង! រៀនព្រឹកល្ងាចណា!

កៈ បាទ!

ខៈ មួយថ្ងៃប៉ុន្មានម៉ោងគិតមើលមើ? ព្រឹកព្រលឹមឡើងដឹងតាព្រឹមៃតាំងពីម៉ោង៨ដល់ម៉ោង១១ អញ្ចឹងចូលម៉ោង២ដល់ម៉ោង៥ ដល់តាចូលដល់កាលេសវា គេហៅកាលេសមិនមែនលីសសេទេកាលហ្នឹង។

កៈ បាទ! កាលេស!

ខៈ ដល់តាពេលស្រុកគេឥឡូវនេះបានហៅ លីសសេហើយអត់បាច់ធ្វើនៅតាកែវនៅអីទេ កាលេស។

កៈ ហើយអឺ! ក្រៅពីភាសាខ្មែរលោកអ៊ុំមានចេះភាសាអីដែរ?

ខៈ បារាំងដែរតើ តែឥឡូវភ្លេចអស់អាលីង។

កៈ អូ! អញ្ចឹងបារាំងតិចតួចដែរ!

ខៈ ហ៊ឺ! បារាំងរហូតហាស់បារាំងរៀនតាំងពីថ្នាក់ទី៩ទៅហាស់ ថ្នាក់ទី៩។

កៈ កាលហ្នឹងកាលនៅរៀនហ្នឹងចេះច្រើនដែរអញ្ចឹង?

ខៈ កាលនៅរៀនចេះច្រើនដល់តាពេលឈប់មានអី អត់ប្រើផងមករៀនអង់គ្លេសណាស្អុយ!

កៈ អូ!

ខៈ ក្មួយខ្ញុំខឹងតើមិនរៀនបារាំងរៀនអីទេ បើរៀនបារាំងវាចេះជាងវាចេះស្រាប់ហាស់។

កៈ បាទ!ៗ។

ខៈ ចុះមេរៀនសុទ្ធតាបារាំង។

កៈ មិញលោកអ៊ុំរៀនបានកំរិតថ្នាក់ទីអឺ!

ខៈ ទីចប់ថ្នាក់ទីបី ថ្នាក់ទីបីប្រលងឌីផ្លូម ប្រលងឌីផ្លូមឆ្នាំ១៩៧០ចូលធ្វើការអញ្ចឹងទៅណា។

កៈ បើនិយាយពីឥឡូវប្រហែលខ្ទង់ថ្នាក់ទី១០អីមើលទៅ?

ខៈ ទី១០!

កៈ ហើយសាលាដែលលោកអ៊ុំទៅរៀនកាលហ្នឹងនៅណាដែរលោកអ៊ុំ?

ខ៖ នៅចំបក់ ជិះកង់ពីសាលាទៅផ្ទះពីរគីឡូហាស់។

ក៖ នៅចំបក់។

ខ៖ ២គីឡូពីផ្ទះទៅប្អូនជើងក្នុងមួយថ្ងៃហាស់។

ក៖ ខេត្តតាកែវហ្នឹង?

ខ៖ អត់ទេខេត្តតាកែវដែរ ប៉ុន្តែនៅស្រុកបាទី។

ក៖ អូ! ស្រុកបាទី!

ខ៖ ហ្នឹងហើយ ចំបក់ហ្នឹងហួសសំរោង។

ក៖ សាលាហ្នឹងឈ្មោះអីគេលោកអ៊ុំ?

ខ៖ គេដាក់ៗ ឥឡូវគេដាក់អនុវិទ្យាល័យចំបក់ហ៊ុង ចំបក់ហ្នឹងហ៊ុងឈ្មោះចំបក់ហ្នឹងហ៊ុងហាស់ អត់កែអត់កែប្រែទេ ប៉ុន្តែវាបង្កើតជាលីុសសេ ហៅលីុសសេចំបក់ហ្នឹងហ៊ុង។

ក៖ បាទ!ៗលោកអ៊ុំ។ តើលោកអ៊ុំមានមិត្តភ័ក្រស្និទស្នាលដែលធំធាតុជាមួយលោកអ៊ុំទេ?

ខ៖ ស្លាប់អស់ហើយ! ស្លាប់អស់អាលីងហ៊ុងអត់មានសល់ អត់មានស្លាប់អស់អាលីង។

ក៖ អញ្ចឹងអត់មានអ្នកណានៅទេអញ្ចឹងមិត្តភ័ក្រលោកអ៊ុំ?

ខ៖ អត់សោះមិត្តភ័ក្រ មានមានតែមិត្តភ័ក្រថ្មីៗឥឡូវ ពីមុនអត់មានសោះ។

ក៖ ចុះតាំងពីតូចរហូតដល់អាយុប៉ុណ្ណឹងលោកអ៊ុំធ្លាប់ប្រកបមុខរបរអីខ្លះដើម្បីចិញ្ចឹមជីវិត?

ខ៖ ខ្ញុំនៅជំនាន់លុននុលធ្វើការដែរហ្នឹង ខ្ញុំធ្វើការខាងទទួលទូរស័ព្ទហាស់ អាឡូៗហ្នឹង។

ក៖ អ៎! ខាងទទួលទូរស័ព្ទ។

ខ៖ ចាំ! ខាងទទួលទូរស័ព្ទ។

ក៖ ហើយចុះឥឡូវលោកអ៊ុំ?

ខ៖ ពេទ្យ!

ក៖ អ៎!

ខ៖ អូ! ខ្ញុំចូលមកខ្ញុំធ្វើពេទ្យ ខ្ញុំចប់ហើយខ្ញុំរីត្រៃត។ ឥឡូវមិនបាច់នេះទេអ្នករីត្រៃតហ្នឹងគេអត់យកលុយទេចូលពេទ្យរដ្ឋហាស់ ខ្ញុំទើបតែលឺក្មួយខ្ញុំប្រាប់ពីម្សិល។

ក៖ ចុះច្បាប់ប្រាក់រីត្រៃតបានប៉ុន្មានដែរ?

ខ៖ បាន៥០ម៉ឺន ៥២ឥឡូវបានឡើងបាន៥២ហើយ ប៉ុន្តែឥឡូវគេឲឡើងទៀតអត់ដឹងប៉ុន្មានទេ គេមិនឲឡើងអ្នកធ្វើការអ្នកក្រៅក៏ឲឡើងដែរណា អត់ដឹងថាគេឲប៉ុន្មាន២០ភាគរយ អត់ដឹងចាំមើលបើកលុយខែហ្នឹង ប៉ុន្តែគេមិនទាន់ធ្វើទេបែប។

ក៖ បើអញ្ចឹងសព្វថ្ងៃលោកអ៊ុំបានប្រាក់រីត្រៃត!

ខ៖ ហ៊ី! បើមិនបានប្រាក់រីត្រៃតចាយអ្នកណាឲយើងចាយ! អាគេឲយូរៗម្តងហ្នឹង។

ក៖ បាទ!

ខ៖ បានអីស៊ី? ង៉ាប់ហើយខ្ញុំបានព្រះចិញ្ចឹមទេណា គុណបុណ្យខ្ញុំហើយហ្នឹងណា។

ក៖ បាទ!ៗលោកអ៊ុំ។ ចុះតាំងពីវ័យក្មេងរហូតដល់ពេលនេះ ជីវិតលោកអ៊ុំមានការផ្លាស់ប្តូរអ្វីខ្លះដែរលោកអ៊ុំ?

ខ៖ អូ! ខ្ញុំពិបាកណាស់ អារក្សធ្វើទុក្ខណាស់ឥឡូវហ្នឹង ប៉ុន្តែឥឡូវខ្ញុំជាអស់វិញហើយណា អារក្សវ៉ៃខ្ញុំច្រើនណា វ៉ៃខ្ញុំច្រើនណាស់ ហើយជូនកាលអត់ធ្វើតាមវាទេ ខ្ញុំងង៉ុយដេកខ្ញុំឈប់ធ្វើម៉ោង១០ ខ្ញុំលែងធ្វើដូចមុនហើយទល់ៗភ្លឺ បើវាចង់ឲធ្វើម៉ោង៥ម៉ោងអីអញ្ចឹងទៅចាំដាស់ខ្ញុំធ្វើទៀត បើធ្វើមិនទាន់ហើយចាំស្អែកមួយថ្ងៃទៀតអញ្ចឹងទៅណា។

ក៖ ហ្នឹង!

ខ៖ គេធ្វើបាប។

ក៖ លោកអ៊ុំស្រីអាសាអធិស្ឋានអី!

ខ៖ អធិស្ឋានខ្ញុំសួរព្រះថាហេតុអីអ៎! បិតាហេតុអីក៏អារក្សឲខ្ញុំធ្វើឲទូលបង្គំធ្វើការធ្វើជាមួយវាអីក៏យប់ម្លេះ? ហេតុអីអានព្រះគម្ពីរធ្វើឲខ្ញុំចុកជើង ទូលបង្គំចុកជើងអានមិនកើតអានដំតាឈរអានអីអញ្ចឹងអីណា។

ក៖ បាទ!ៗ។

ខ៖ ធ្វើៗបានឆ្លើយតបទៅ ជូនកាលយើងស្តាប់យល់ព្រះវិញ្ញាណប្រាប់វាអត់ចង់ឲយើងអានគម្ពីរអីអញ្ចឹងណា។

ក៖ បាទ!ៗ។

ខ៖ ហ៊ឺ! និយាយមិនអធិស្ថានមិចរាប់អធិស្ថាន។

ក៖ ហើយលោកអ៊ុំអឺ! លោកអ៊ុំមានម្ហូបណាដែលលោកអ៊ុំចូលចិត្តទេលោកអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តហាស់!!! សម្លរម្ជូរគ្រឿងហាស់!!!។

ក៖ អញ្ចឹងសម្លរម្ជូរគ្រឿងអញ្ចឹងហែស!

ខ៖ ហ្នឹងហើយម្ជូរគ្រឿងសាច់គោឆ្ងាញ់ណាស់។

ក៖ អញ្ចឹងម្ជូរគ្រឿងសំណាប់របស់លោកអ៊ុំហើយអញ្ចឹង?

ខ៖ ហ្នឹងហើយឆ្ងាញ់ការីនៅចាញ់ម្ជូរគ្រឿងដែរ។

ក៖ ចុះបើនិយាយពីល្បែងប្រជាប្រិយវិញលោកអ៊ុំចូលចិត្តអ្វីដែរ?

ខ៖ ចូលចិត្តដែរ ចូលចិត្តមើលដែរបទរាំងវង្សរាំក្បាច់។

ក៖ និយាយពីល្បែង?

ខ៖ ល្បែងអីគេ?

ក៖ ដូចលេងឈូង បោះអង្គុញអី?

ខ៖ អ៎! អាហ្នឹងក៏ចូលចិត្ត ចូលចិត្តចូលចិត្តលេងទាំងអស់តាំងនៅពីក្មេង ក្រាបមាន់ស្គាល់ពាក្យអាមាន់រងាវគេធ្វើលេងល្បែងក្រាបមាន់អាពេលចូលឆ្នាំហ្នឹងណា បោះអង្គុញចោលលេងទាំងអស់។

ក៖ អូ!

ខ៖ ចូលគ្រប់ល្បែង។

កៈ ចុះអ៎! តើអ៊ុំចងចាំចម្រៀងណាដែរលោកអ៊ុំបានរៀនតាំងពីក្មេងៗរហូតដល់ពេលនេះទេលោកអ៊ុំ?

ខៈ ចម្រៀងអីគេ?

កៈ ចម្រៀងដែលលោកអ៊ុំចូលចិត្តច្រៀងលេងអី!

ខៈ ច្រៀងលេងហ្នឹង ឥឡូវខ្ញុំច្រៀងតាបទអារក្សធ្វើទុក្ខពេកខ្ញុំច្រៀងបទខ្ញុំជាកូនរបស់ព្រះហើយអញ្ចឹងទៅ។

កៈ ចុះអាចម្រៀងហាស់!!! យើងស្ដាប់អីហ៎?

ខៈ អ៎!

កៈ ចម្រៀងអ្នកចម្រៀងយើងហ្នឹង!

ខៈ ចូលចិត្តដែរ។

កៈ ចុះរបស់អ្នកណាគេដែរលោកអ៊ុំ?

ខៈ ចូលចិត្តរបស់ រស់ សេរីសធា។

កៈ បាទ! លោកអ៊ុំ។

ខៈ ប៉ែន រន ក៏ចូលចិត្តដែរ វាច្រៀងកាលពីខ្ញុំនៅក្មេងពេលវាទៅតាមសម្ដេចអីចឹងហាស់ខ្ញុំទៅទទួលសម្ដេចអីចឹង។

កៈ អ៎!

ខៈ គេនេះដែរ គេច្រៀងក្មេងៗដូចថាទៅដល់កន្លែងហួសភ្នំជីសូអីចឹងសាលាគេអាខ្លះសាលាគេនេះហ្មង គេក្លាហានក្មេងៗឡើងច្រៀងណា។

កៈ បាទ!ៗ។

ខៈ ឡើងច្រៀងលើវេទិកាទំរាំសម្ដេចមក។

កៈ បាទ! ហើយលោកអ៊ុំនៅក្នុងក្រុមគ្រួសាររបស់លោកអ៊ុំមានអ្នកណាគេចេះលេងឧបករណ៍ភ្លេងទេ?

ខ៖ អត់ អត់មានចេះទេ។ អូ! អាចៅមាននៅក្នុងក្រុមគ្រួសារឥឡូវនេះអត់ អានោះកូនចៅកូនក្មួយនោះអត់ ខ្ញុំមានចៅ ប្អូនរបស់ខ្ញុំគាត់មានចៅ។

ក៖ បាទ!ៗ។

ខ៖ អាមួយហ្នឹងធំជាងគេអាមួយហ្នឹងរៀនឆ្នាំទីពីរហើយ ប៉ុន្តែខ្ញុំមើលទៅវាទៅវាដូចអត់មានស្រីមានសង្សារអីទេ វាដេកវាមកពីសាលាវិញ រៀនហើយវាដេកដេកហើយវាដឹងតារៀន វាអត់ចេះធ្វើខ្លួនអញ្ចឹងបានតាវាហាស់!!!

ក៖ អ៎!!!

ខ៖ ហាស់!!! ខ្ញុំចូលចិត្តអញ្ចឹង។

ក៖ បាទ!ៗ លោកអ៊ុំ។ ហើយលោកអ៊ុំតើមានជំនាញអ្វីខ្លះដែលលោកអ៊ុំបានរៀនបន្តវេនពីក្រុមគ្រួសាររបស់លោកអ៊ុំ? ដូចជា៖ ជំនាញវេញវល្លិ៍ផ្ដៅ ជំនាញ។

ខ៖ អូយ! អត់ចេះសោះ។

ក៖ ធ្វើស្ករត្នោតអី?

ខ៖ អូយ! អត់ចេះទេ។

ក៖ អញ្ចឹងមានជំនាញអីក្រៅពីហ្នឹងដែលលោកអ៊ុំបានរៀនពីដូនតា?

ខ៖ មានតាខ្ញុំរៀន ខ្ញុំអត់អ៎! គ្រាន់តាអុំអង្ករតិចតែឥឡូវធ្វើលែងកើតហើយឈឺចង្កេះហើយហាស់!!!

ក៖ ហាស់!!!

ខ៖ អឺ! មានតែធ្វើស្រែ ធ្វើស្រែហ្នឹងខ្ញុំអត់ចេះពីគ្រួសារទេណា ខ្ញុំចេះជំនាន់អាពតហ៎!

ក៖ អាពតបង្រៀន!

ខ៖ ចា៎!

ក៖ អត់បានរៀនពីប៉ាម៉ាកទេ។

ខ៖ អត់ទេអត់ចេះ ម៉ែឪគិតតាជួលគេហ្នឹង។

ក៖ អូ!

ខ៖ ជួលតាគេយកមកស្ទូងហ្នឹងធ្វើស្រែ ឪខ្ញុំស្រែច្រើនណាស់ណា សី ហា! ច្រើនណាស់ខ្ញុំអាណិតឪខ្ញុំណាស់ សី ហា អើយ! គាត់ភ្ជួរ គាត់រាស់ រែកកណ្ដាប់ស្ទូង រែកកណ្ដាប់អាស្រូវ ដឹកអាទេះយកអាទេះដឹកស្រូវ អូ! អាណិតឪខ្ញុំយ៉ាប់ណាស់។

ក៖ បាទ!ៗ។

ខ៖ អ្នកធ្វើស្រែយ៉ាប់ណាស់អ្នកធ្វើស្រែ!

ក៖ ហើយលោកអ៊ុំអឺ! តើលោកអ៊ុំអាចប្រាប់ក្មួយពីពេលវេលាដែលលំបាកបំផុតក្នុងជីវិតរបស់លោកអ៊ុំ តាំងពីតូចរហូតដល់ពេលហ្នឹង កំឡុងពេលណាដែលលោកអ៊ុំគិតថាជីវិតរបស់លោកអ៊ុំលំបាក?

ខ៖ ពិបាកៗ ជំនាន់អាពតពិបាកណាស់ អត់មានស្អីហូបទេចេញពីអាពត ចេញពីអាពតមកអត់មានខោអាវតែម៉ាចង្កេះខ្ញុំអូសកំពឹស មានម៉ុងមានម៉ុងខ្លួនឯងសល់ហាស់ អាហ្នឹងអញ្ចឹងពីនាក់ប្អូនអូសកំពឹស ហើយយកទៅដូរអង្ករ ដូរអង្ករបានអាហ្នឹងៗ វេទនាជំនាន់អាពតផ្សេងទេណា។

ក៖ បាទ! អ៊ុំ។

ខ៖ ចេញពីអាពតមកវេទនាខំប្រឹងលើសជាងអាពតទៀត ហើយដល់ពេលឥឡូវនេះឈឺចាប់ណាស់ អារក្សធ្វើទុក្ខណាស់ ឥឡូវវាបានធូរស្រាលជាងមុនបន្តិចហើយ។

ក៖ បាទ! លោកអ៊ុំ។

ខ៖ កាលមុនធ្វើទុក្ខអើយធ្វើ ឃើញស្រាប់ហើយខ្ញុំស្រកសាច់ណាស់ណា។

ក៖ បាទ! លោកអ៊ុំ។

ខ៖ កាលមុនហើមទេណា។

ក៖ បាទ!

ខ៖ កាលមុនហើមអញ្ចឹងវាអត់នោម អញ្ចឹងមុនហ្នឹងគេធ្វើឲខ្ញុំនេះអញ្ចឹង គេខ្ទាស់សសៃខ្ញុំទាំងអស់ ខ្ទាស់សន្លាក់ខ្ញុំទាំងអស់ ខ្ញុំនិយាយអត់កើតទេកាលហ្នឹងនិយាយកើតដែរប៉ុន្តែតាឡាន់ និយាយដូចជាប់តាដឹតហាស់។

ក៖ បាទ!ៗ លោកអ៊ុំ។

ខ៖ ខ្ទាស់ទាំងអស់គេចងមាត់គេចងអូយ! ចងទាំងអស់សីហាអឺ! ទំរាំតែស្រាយហើយគេ អូ! ឥឡូវវាស្រាយចង់អស់ហើយជិតអស់ហើយ។

ក៖ បាទ! លោកអ៊ុំ។ ហើយនៅពេលដែលលោកអ៊ុំជួបភាពលំបាកក្នុងជីវិតរបស់លោកអ៊ុំហ្នឹង លោកអ៊ុំធ្វើការតាំងចិត្តយ៉ាងមិចដើម្បីយកឈ្នះវា?

ខ៖ អធិស្ថាន អធិស្ថានហើយអញ្ចឹង ខ្ញុំយកឈ្នះខ្ញុំមកព្រះគម្ពីរ អំ! មកព្រះវិហារអានព្រះគម្ពីរអញ្ចឹង ខ្ញុំយកឈ្នះវាហើយណា។

ក៖ បាទ! លោកអ៊ុំ។

ខ៖ អធិស្ថានគឺមកព្រះវិហារអត់ខាន ប្រសិនបើខ្ញុំអត់មកព្រះវិហារវារិតតែធ្វើទុក្ខឲខ្ញុំឈឺខ្លាំងទៀត។ ខ្ញុំអត់អានព្រះគម្ពីរក៏រិតតែធ្វើទុក្ខខ្ញុំ។

ក៖ បាទ!ៗ។

ខ៖ អញ្ចឹងខ្ញុំត្រូវតែអាន ត្រូវតែមកព្រះវិហារហើយអធិស្ថានគោរពច្បាប់ទាំងអស់ ដង្វាយអត់មានកិបអីមួយរៀលទេណា។

ក៖ បាទ!ៗ លោកអ៊ុំបាទ! តើលោកអ៊ុំមានបទពិសោធណាខ្លះដែលល្អៗនៅក្នុងឆាកជីវិតរបស់លោកអ៊ុំ ដូចជា៖ ពេលដែលកូនចៅរៀបអាពាហ៍ពិពាហ៍ ឬក៏អ៊ុំធ្វើអីមួយ បទពិសោធដូចជាតាំងពីក្មេងរហូតដល់ពេលនេះពេលណាដែលលោកអ៊ុំគិតថាវាសប្បាយធ្វើ ឲសប្បាយ?

ខ៖ ធ្វើឲយើងសប្បាយចិត្តហ្នឹងហែស?

ក៖ មានអារម្មណ៍សប្បាយចិត្ត?

ខ៖ ធ្វើឲសប្បាយចិត្ត ខ្ញុំអត់ដែលនេះទេខ្ញុំអត់មានពេលសប្បាយសោះហើយ។

ក៖ បាទ!

ខ៖ ដឹងខ្លួនវេទនារហូត។

កៈ បាទ!ៗ លោកអ៊ុំ។

ខៈ ដឹងខ្លួនអារក្សធ្វើទុក្ខ ទុក្ខអារក្សៗ ដូចខ្លួនខ្ញុំទុក្ខអារក្សកម្មអញ្ចឹងណា!

កៈ បាទ!ៗ លោកអ៊ុំ។

ខៈ វាទុក្ខក្នុងខ្លួនខ្ញុំហ្នុងហ្នឹងហា៎!

កៈ បាទ! អញ្ចឹងនៅពេលដែល លោកអ៊ុំនៅវ័យក្មេងតើធ្លាប់មានអី! សង្ឃឹមចង់ធ្វើអ្វីដែរហើយនៅពេលដែលលោកអ៊ុំធំឡើងសមដូចបំណងប្រាថ្នាទេលោកអ៊ុំ?

ខៈ នៅវ័យក្មេងអត់ចង់ធ្វើស្រែទេ ខ្ញុំឃើញឪខ្ញុំពិបាកពេកខ្ញុំខឹងជាមួយឪខ្ញុំដូចៗយើង ខ្ញុំខឹងជាមួយម៉ែឪខ្ញុំដែរតើ ខ្ញុំជូនកាលខ្ញុំ ដ៏ខឹងជាមួយម៉ែឪខ្ញុំ ខឹងរឿងអី ឪខ្ញុំវ៉ៃចង់វ៉ៃខ្ញុំឆ្លូសគ្នាជាមួយបងខ្ញុំអញ្ចឹងទៅ វ៉ៃដេញខ្ញុំ ខ្ញុំរត់ខ្ញុំខ្លាចឪខ្ញុំវ៉ៃ ពីរនាក់បងឆ្លូសគ្នាហើយរត់ទៅផ្លូវតែមួយទៀត មិនមែនទៅខុសគ្នាទេណា។

កៈ បាទ!

ខៈ ទៅផ្លូវទៅផ្ទះបងម៉ែខ្ញុំ បងម៉ែខ្ញុំថាឲមកផ្ទះវិញអញ្ចឹងឪហែងវ៉ៃង៉ាប់ហើយ អញ្ចឹងមានម្នាក់មួយទៀតនៅផ្ទះជាប់គ្នា ម៉ែឪក៏វ៉ៃដូចគ្នាអញ្ចឹងរត់នាំគ្នាទាំងបីនាក់ហ្នឹង បងខ្ញុំហើយមួយទៀតហ្នឹងក៏រត់ដែរ ប៉ុន្តែគាត់នៅរស់ហាស់។

កៈ បាទ!ៗ។

ខៈ គាត់អាយុបងខ្ញុំច្រើន អញ្ចឹងគាត់ទៅនៅផ្ទះបងប្អូនមួយទៀតនោះ នៅកន្លែងត្រពាំងសាបដែលខ្ញុំថា អាមួយដែលខ្ញុំថាអាពតហ្នឹងហាស់ អញ្ចឹងអាពតដល់ពេលហើយដឹងថា
ឪខ្ញុំស៊ើបម៉ែឪខ្ញុំដឹងជាមួយផ្ទះមួយទៀតដឹងថាស៊ើបទៅនៅហ្នឹង
បានទៅហៅខ្ញុំមកវិញខ្លាចវ៉ៃណាស់ខ្លាច ហើយចង់តែដើរស៊ីឈ្នួលគេ អត់ចង់នៅជាមួយគាត់ទេព្រោះគាត់អត់មានអីស៊ីបងប្អូនច្រើនសីហា។

កៈ បាទ!ៗ លោកអ៊ុំ។

ខៈ ស្រែច្រើនមែនមានតែស្រូវអង្ករ តែខ្វះខាតច្រើនណាស់អត់មានអីស៊ីទេ ស្រែធ្វើមិនបានផលទេច្រើនពេកថៃអត់ទាន់អត់មានអីថៃអត់មានដាក់ជី។

កះ បាទ! លោកអ៊ំ។ បើសិនជាលោកអ៊ំស្រីអាចផ្ដាំអ្វីមួយទៅកាន់កូនចៅរបស់លោកអ៊ុំជំនាន់ក្រោយៗ តើលោកអ៊ំស្រីនឹងប្រាប់អ្វីខ្លះទៅកាន់ពួកគេ?

ខះ ខ្ញុំប្រាប់ធគេ!

កះ ដូចជាបណ្ដាំចុងក្រោយផ្ដាំទៅកូនៗ?

ខះ អូ! ធខំរៀនហើយកុំធខ្ជិលច្រអូសហ្នឹងណា មានអីធយើងយកបទជំនាញធបាន ជំនាញអីមួយធច្បាស់លាស់បានជួយខ្លួនយើងបាន
បើអត់ច្បាស់លាស់ឥឡូវស្រុកគេចង្អៀតណាស់ ដ៏អញ្ចឹងចេះហាស់។

កះ បាទ! លោកអ៊ុំ។

ខះ ផ្ដាំធធ្វើអញ្ចឹងកុំធខ្ជិល។

កះ បាទ! លោកអ៊ុំ ហើយលោកអ៊ុំមានអ្វីទៀតចង់ផ្ដាំទៅកាន់ពួកគាត់ទៀតអត់?

ខះ ហើយធធ្វើចរិកធរាបសារ។

កះ បាទ! លោកអ៊ុំ។

ខះ សុភាពរាបសារ ជាកូនខ្មែរយើងសុភាពណា!

កះ បាទ!

ខះ ខ្ញុំក៏សុភាពដែរ ប៉ុន្តែដល់តាពេលខ្ញុំខឹងខ្ញុំជេរ៉ា!

កះ បាទ! លោកអ៊ុំ។

ខះ ហ្ង! ខ្ញុំសុភាព ខ្ញុំមិនថាខ្លួនខ្ញុំសុភាពទេ គេអ្នកក្រៅមើលមកខ្ញុំថាខ្ញុំសុភាពហាស់!!! ប្រធានខ្ញុំមិនដែលរវល់ទេប្រុសៗ។

កះ បាទ!ៗ។

ខះ ហើយកុំសង្ស័មថាខ្ញុំយកប្ដីអីនោះអត់ទេ មកធ្វើទេសធ្វើអីខ្ញុំអត់ទេខ្ញុំគ្មានមកយកហ៊ី! មកធ្វើខ្ញុំស្អប់អាណាមកសួរអញ្ចឹង សួររបៀបធ្វើទេសហាស់។

កះ បាទ! លោកអ៊ុំ។

ខ៖ អត់ទេអត់ចូលចិត្តទេមនុស្សចំនាស់នេះហើយយកមកធ្វើអីលោកអើយ! អាណាបម្រើឯងបម្រើតែខ្លួនឯងមិនរួចផង។

ក៖ អញ្ចឹងអរគុណច្រើនលោកអ៊ុំដែរបានជួបពិភាក្សាជាមួយនិងក្មួយលោកអ៊ុំ។

ខ៖ ចា៎!

ក៖ ហើយមុននឹងបញ្ចប់ប្រហែលជាក្មួយសំថតរូប លោកអ៊ុំមួយទុកជាអនុសាវរីយ៍ តើលោកអ៊ុំអនុញ្ញាត ឲក្មួយធ្វើការដាក់រូបថត និង បទសម្ភាសនេះនៅលើគេហទំព័ររបស់សាកលវិទ្យាល័យBrigham Young បានដែរឬទេលោកអ៊ុំ?

ខ៖ បាន! អត់កុំណាញ់ទេ។

ក៖ បាទ! អញ្ចឹងអរគុណច្រើនលោកអ៊ុំ សាកលវិទ្យាល័យនឹងផ្ដល់ជូនលោកអ៊ុំស្រីនៅថតចម្លងមួយច្បាប់ នៃបទសម្ភាសនេះដល់លោកអ៊ុំស្រី ហើយលោកអ៊ុំស្រីឬក៏កូនចៅអាចចូលទៅស្ដាប់វានៅលើគេហទំព័រ ដែលក្មួយធ្វើសម្ភាសលោកអ៊ុំហ្នឹង។

ខ៖ ចា៎!

ក៖ នៅពេលណាមួយក៏បានដែរ ហើយឈ្មោះគេហទំព័រហ្នឹងដូចក្មួយបានប្រាប់លោកអ៊ុំខាងដើម ខាងដើមហ្នឹងវាមានឈ្មោះថា www.cambodianoralhistories.byu.edu។

ខ៖ កត់ឲខ្ញុំតិចមកខ្ញុំចង់ ក្រែងថ្ងៃណាមួយឲកូនចៅ គេមានអ៊ីនធើណែតរបស់គេហាស់។

ក៖ បាទ! អញ្ចឹងអរគុណច្រើនលោកអ៊ុំ ក្មួយមានតែប៉ុណ្ណឹង សូមជំរាបលាបាទ!

ខ៖ ចា៎! ជំរាបលា!